# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ១ លេខ ៩

ខែមិថុនា-កក្កដា ព.ស. ២៤៩៣

ឆ្នាំសិក្សា ១៩៤៩-១៩៥០

ព្រះរាជាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

## សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង


| | ទំព័រ |
|---|---|
| វេយ្យាករណ៍ | ១ |
| ឧត្តមដ្ឋាន | ៣ |
| មជ្ឈិមដ្ឋានទី ២ | ៦ |
| — — ទី ១ | ៧ |
| អាទិកដ្ឋាន | ១០ |
| មេសូត្ររត់មាត់ | ១៨ |
| មជ្ឈិមដ្ឋានទី ១ នព្វន្ត | ២៣ |
| រង្វាស់រង្វាល់ | ២៦ |
| ធរណីមាណសាស្ត្រ | ២៩ |
| បរិវច្ឆណដ្ឋាន នព្វន្ត | ៣២ |
| កុមារដ្ឋាន នព្វន្ត | ៣៤ |

# វេយ្យាករណ៍

ខែនេះនៅទីចុងឆ្នាំ ការបង្រៀនភាសាខ្មែរគប្បីសើរើរៀនឡើងវិញមេរៀនដែលបានរៀនរួចហើយ និងឲ្យរៀននិបាតសព្ទបញ្ចប់ ។ វិធីប្រើអោយតនិបាតជាការសំខាន់ក្នុងភាសាខ្មែរ សុំលោកគ្រូទាំងឡាយបង្ខំឲ្យសិស្សមើលឡើងវិញរឿយៗ (ទស្សនាវដ្តីខែមេ១៩៤៨ ទំព័រពី ៣៦ ទៅ ៣៨)

ឧត្តមដ្ឋាន

---

# ខ្ញុំទៅកំសាន្តបិត្តងកែប

នៅពេលចូលឆ្នាំខ្មែរបីថ្ងៃ ឪពុកខ្ញុំបាននាំខ្ញុំទៅលេងឆកខ្យល់អាកាសឯកែប ។

ម៉ោង៦ព្រឹក លុះរៀបចំសំពត់អាវដាក់ក្នុងវ៉ាលីសនិងម្ហូបអាហារសំរាប់ទទួលទានតាមផ្លូវស្រេចហើយ ខ្ញុំឪពុកនិងម្ដាយខ្ញុំក៏ចេញដំណើរទៅដោយឡានឈ្នួលតូចមួយ ។ នៅតាមផ្លូវខ្ញុំបានឃើញភូមិនិងស្រុកគេ ដ៏មានផ្ទះឯកៗពីគ្នា ផ្ទះអប់ទាំងនោះច្រើនសង់នៅជុំគ្នា ។ ទៅពីក្រុងពេញប្រ-ហែលជាសែសិបគីឡូម៉ែត្រ ខ្ញុំឃើញនៅខាងស្តាំដៃខ្ញុំ ភ្នំមួយមានព្រះវិហារនៅលើកំពូល ដែលគេហៅថាភ្នំជីសូរ ហើយនៅឆ្ងាយដាច់កន្ទុយភ្នំគេឃើញផ្លូវក្រុងកំពត ៗ ដល់ឡានចម្ងាយប្រហែលមួយរយគីឡូម៉ែត្រ ខ្ញុំទៅដល់ទ្វារកំពត ។ នៅសងខាងផ្លូវមានភ្នំៗដែលនៅខាងស្តាំដៃ មិនសូវមានថ្មទេ ហើយមានដុះដើមឈើជិតៗគ្នា ខ្ពស់ៗមានវល្លិ៍ព័ន្ធ ៗ នៅខាងឆ្វេងវិញ ខ្ញុំឃើញភ្នំមួយទៀត មានសុទ្ធតែថ្ម មានក្រហែងក្រហូង ព្រោះបារាំងបានឲ្យកាប់បំបែកថ្មនោះមកក្រាលផ្លូវថ្នល់ ៗ លុះម៉ោងប្រាំបួន ខ្ញុំទៅដល់ផ្សារកំពត ខ្ញុំនិងឪពុកខ្ញុំក៏ឈប់នៅទីនោះបន្តិច ដើម្បីនឹងមើលទីផ្សារ ហើយនឹងទិញអីវ៉ាន់យកទៅទទួលទានផង ។ ផ្សារនោះសប្បាយណាស់មានទំនិញស្ទើរតែគ្រប់មុខ ខ្ញុំឃើញមានកាពិយ៉ាន់ឈ្មួញ ដែលគ្រាន់តែជុំក្នុងទឹក

ឃ្លានបាយ ។ មានទឹកត្រជាក់ មានសាច់ងៀតគ្រប់មុខ គឺងៀតត្រីផ្ទោង សមុទ្រ ងៀតបថែល ងៀតឆ្លាមហើយនិងងៀតឯទៀតជាច្រើន ដែលខ្ញុំមិនស្គាល់ឈ្មោះ ។ មានលក់បន្លែនិងលក់ផ្លែឈើថ្មីៗពីទីក្រុងភ្នំពេញ ។ នៅខាងក្រៅផ្សារ មានលក់មាក់ប្រាង សារម៉ាវ សេមាន ម្នាស់កំពង់ មានធុរេនសម្បូរ មានផ្លែគុយ ផ្លែព្រួសនិងផ្លែឈើច្រើនទៀត ដែលគេបានមកពីភ្នំ ។ ក្នុងផ្សារតូចមួយដែលសង់នៅមាត់ដៃសមុទ្រ មានលក់ត្រី លក់ងាវ លក់កំពឹស ក្តាមសេះ សារាយ ហើយនិងមានលក់ផ្អក ងាវ យូហ៊ី ប៉ង្កៀ ត្រីឆ្អើ ត្រីអណ្តែងទន់ ។ លុះទិញអីវ៉ាន់បានស្រេចហើយ ខ្ញុំនិងឪពុកខ្ញុំក៏ចេញដំណើរទៅកែបទៀត ។ ទៅតាមផ្លូវខ្ញុំឃើញមានសួនដូង ចំការម្រេចដែលមានជួរនិងជួរជាប់ លុះជិតទៅដល់កែប ខ្ញុំធុំក្លិនសារាយ ខ្យល់បក់នាំយកមកពីសមុទ្រ មិនយូរប៉ុន្មាន ខ្ញុំឃើញសមុទ្រកែបធំឥតឃើញត្រើយ ដ៏មានភាពដូចជាកំរាលមួយសស្អាត ។ លុះទៅដល់កន្លែងដែលគេធ្វើសំរាប់ទុកឲ្យភ្ញៀវងូតទឹក យើងតាំងស្នាក់ឈប់នៅទីនោះ យកម្ហូបនិងបាយមកនាំគ្នាទទួលទានលើស្មៅនៅជើងភ្នំជិតមាត់សមុទ្រ ព្រោះថ្ងៃជិតត្រង់ហើយ ។ ឃើញទឹកសមុទ្រខ្ញុំនឹកសប្បាយហើយចង់តែចុះទៅងូតលេង ប៉ុន្តែខ្ញុំមិនហ៊ាន ព្រោះខ្លាចចិត្តឪពុកខ្ញុំ ខ្ញុំនឹកតែសប្បាយពុំចេះដាច់ ។ ទទួលទានរួចស្រេចហើយយើងទៅឈរលេងនៅផ្ទះតូចមួយ ដើម្បីនឹងឲ្យជាតិអាហាររត់ស្រួល និងចាំឲ្យមេឃស្រទំបន្តិច ។ ខ្ញុំឃើញរលកធំៗផាត់មកប៉ះនឹងច្រាំងដ៏មានសូរ

ក្រាំងៗ មានមនុស្សជាច្រើនងូតទឹកកក្រញាកលោតហែលលេងសប្បាយ ៗ ឃើញគេលេងជូប្រះ ខ្ញុំរឹតតែចង់ងូតណាស់ទៀត ៗ ប្រហែលកន្លះម៉ោងតមក ខ្ញុំក៏ចុះងូតទឹក មុនដំបូងខ្ញុំមិនហ៊ានទៅឆ្ងាយពីច្រាំងទេ ខ្លាចលង់ហើយខ្លាចសមុទ្រផង ៗ លុះខ្ញុំឃើញគេទៅច្រើននាក់ ខ្ញុំក៏លុះចិត្តទៅជាមួយនឹងឪពុកខ្ញុំៗទៅប៉ះទឹងចង្កំដែលមានចុះសារាយ ខ្ញុំមិនដឹងក៏ទៅអន្ទុយលេងលើច្ឆនោះ លុះលេបឃើញមកទឹកសាបចូលមាត់ខ្ញុំ ដឹងមានជាតិប្រៃដូចជាទឹកដែលឃើញលាយអំបិល ៗ ខ្ញុំក៏ក្រោកឡើងឈរ ដើម្បីឲ្យផុតលេក ៗ យើងដកសារាយបានច្រើនក៏ត្រឡប់មកខាងវិញ ខ្ញុំអង្គុយលេងលើដីខ្សាច់ រើសសំបកខ្យងល្អៗមកគរទុកដើម្បីយកមកផ្ទះ ៗ ងូតទឹកសមុទ្ររួចហើយ យើងមកលាងខ្លួននឹងទឹកសាបនៅក្នុងបន្ទប់ ហើយយើងនាំគ្នាទៅមើលច្បារកែប ៗ យើងជួលកន្ទប់១នឹងសំណាក់ លុះព្រឹកឡើងកាលណាយើងក៏ត្រឡប់មកវិញតាមផ្លូវកំពត យើងឈ្ងោតចូលទៅមើលកន្លែងមួយដែលហៅថាទឹកឈូរ បណ្ដោយប្រហែលជា១០គីឡូម៉ែត្រ ៗ ទីនោះមានជ្រោះជ្រៅប្រហែល៨ម៉ែត្រ ដ៏មានបាតសុទ្ធថ្មធំៗមានទឹកថ្លាដូចកញ្ចក់ មានដុំថ្មតូចធំសឹងកាន់មូលដូចគ្រាប់កាំភ្លើង ថ្មទាំងនោះសុទ្ធនឹងទឹកហូរ ៗ យើងមើលទីនោះរួចហើយក៏ត្រឡប់មកកំពតរហូតដល់ភ្នំពេញ យើងរឹតតែសប្បាយមិនភ្លេច កាលណាមានឱកាសនឹងទៅលេងម្ដងទៀត ៗ

## មជ្ឈិមដ្ឋានទី ២

# ដើមស្វាយទិព្យឬស្វាយកល្ប

មហាក្សត្រិយ៍មួយព្រះអង្គ បានមកពីព្រៃហិមពាន្ត នូវផ្លែស្វាយទិព្យដែលមានឫទ្ធិអាចធ្វើមនុស្សចាស់ត្រឡប់ជាក្មេងបាន ។ ទ្រង់មិនប្រាថ្នានឹងសោយតែមួយព្រះអង្គឯង ទើបស្តេចត្រាស់ឲ្យយកទៅបណ្តុះដាំ ដើម្បីបានផ្លែច្រើននិងប្រទានចែកដល់រាស្ត្រនុរាស្ត្រផង ។ ស្វាយនោះដុះលូតលាស់ល្អ ។ លុះដល់មានផ្លែនៅក្រោមគល់ស្វាយមានរូងអាសិរពិសជាប្រក្រតី ។ ពិសពស់ក៏ជ្រួតជ្រាបសព្វសព្វាង្គនៃឈើ ។ មានផ្លែមួយនោះព្រះរាជាទ្រង់ឲ្យនាយឧទ្យានបេះផ្លែស្វាយមកថ្វាយ ដើម្បីនឹងសោយ ។ ពួកពិសេសក៏បិទស្វាយដាក់ភាជនៈស្រេចហើយលើកទៅថ្វាយ ។ មនុស្សដែលតែងភ្លក្សព្រះក្រយាស្ងោយក៏យកចំណិតតូចមួយមកភ្លក្សចំពោះព្រះភក្ត្រ ។ ជាតិស្វាយនោះបំពុលអ្នកភ្លក្សស្លាប់ភ្លាម ។ ទ្រង់ទតព្រះនេត្រឃើញហេតុដូច្នោះហើយ ទ្រង់ក៏សរសើរព្រេងសំណាងរបស់ព្រះអង្គក៏បោះបង់ស្វាយពុលចោលទៅ ជាស្វាយដែលគេស្ងួន ខ្ញបពល់គ្នា ។ ក្រោយមកអាសិរពិសលែងនៅក្នុងរូងក្រោមគល់ស្វាយទៅ ។ ស្វាយតែងបង្កើតផលដូចធម្មតា ។ លុះយូរលង់មកពលរដ្ឋម្រាតខ្ទួសិនចាស់ៗជរាទៀតណាស់ បម្រាស់ទិនជាតិកំណើតសៅទៅ ក៏បេះផ្លែស្វាយមួយមកបរិភោគទាំងពីរនាក់ ដើម្បីឲ្យក្ស័យជីវិតទៅ ប៉ុន្តែតាចាស់ផ្លាស់រូបទៅជាក្មេងកំលោះសាច់ឈាមឡើងស្រស់បំព្រង សក់ខ្មៅរលើបរលន់ យាយ

ចាស់ផ្លាស់រាងកាយជាក្រមុំដ៏មានខ្លួនសក្តិសម ដោះទើបនឹងក្រពុំទទឹងទ្រា យាយនិងតាមើលគ្នាពុំស្គាល់ យល់តែសំដី សរីរៈទាំងឡាយក្លាយដោយរិទ្ធិស្វាយទិព្វ កិត្តិសព្ទរន្ទឺខ្ទរដល់ព្រះទិព្វស្រោត ទើបស្ដេចឲ្យបេះផ្លែស្វាយមកថ្វាយ ទ្រង់ឲ្យភក្សមើលដូចប្រវេណី អ្នកភក្សក៏ប្រែក្លាយរូបដូចពលដំរីថ្មីប្រពន្ធនោះឯង ។ ព្រះរាជាក៏សោយជាមួយ និងព្រះរាជវង្សានុវង្ស ព្រះកាយាទៀងជាយុវតីយុវា ទើបព្រះរាជាទ្រង់ឲ្យពិនិត្យមើល ក៏ឃើញហេតុថា ស្វាយនោះទៅជាគុណ ព្រោះមានអាសីពិស ។

---

ពាក្យពន្យល់ .- ទិព្វ ឬ ទិព្យ=របស់សួគ៌ របស់វិសេស ។ - អាសីពិស ឬ អាសិរពិស ឬ អាសីវិស = សត្វមានពិសក្នុងចង្កូម គឺពស់ ។ - ភក្ស = ស៊ីដើម្បីមើលរសជាតិជាដំបូង ។ - សរីរៈ ឬ សរីរ=រាងកាយ ។ ព្រះទិព្វស្រោត=ត្រចៀកស្ដេច(រាជស័ព្ទ) ។

ពាក្យសួរ .- រឿងនេះមានអាថ៌ដូចម្ដេច? (អំពីសេពគប់)

មជ្ឈមដ្ឋាន ទី ១

## ព្យុះសង្ឃរានៅឆ្នាំរោងឆស័កចុល្ល, ១២៦៦ (1904)

នៅក្នុងខែពិសាខ ក្រោយវេលាដែលព្រះបាទស៊ីសុវត្ថិ បានទទួលរាជសម្បត្តិជំនួសពីព្រះបាទនរោត្តម ក្នុងកំឡុង ៥ ឬ ៦ ខែ មានខ្យល់ព្យុះធំនៅក្រុងភ្នំពេញនិងក្នុងខេត្ត បណ្ដាដែលនៅជុំវិញ ។ ខ្យល់ធំព្រមទាំងភ្លៀងរលឹមធំ តាំងពីថ្ងៃល្ងាចហូតអស់មួយយប់ ត្រឹមមួយព្រឹក ។

កាលដើមឡើយ គេឃើញពពកខ្មៅពាសពេញ ដូចជាមេឃធ្ងន់ទាប ហាក់ទប់ទំងន់ពុំបាន ។ មួយស្របក់មក ខ្យល់ធ្លាក់កើយ ព្រមទាំងរលិម ។ ខ្យល់បក់ខ្លាំងឡើងបន្តិចៗ ដូនមកពីឯលិច ដូនពីឯត្បូង ដូនពីឯជើង ខ្យល់កាន់តែខ្លាំងឡើងៗ ស័ព្ទសន្ធឹកគ្រឹកគ្រាក់ដូចជាគេទំលាក់ឬរំលំភ្នំ ឈើព្រៃក្យា លតាវល្លិ៍ញាប់ញ័ររវើក ផ្ទះអ្នកស្រុករបើកជញ្ជាំង បើងដំបូល ទឹកភ្លៀងចូល ដូចនៅកណ្តាលវាល ទីវាលដូចជាគោគោលខ្លាល មនុស្សម្នាមហាជន ពួនសំងំឲ្យជែកប្រោន សត្វពាហនក៏ផ្តួលផ្តាក់ ក្រញោលចេញពីក្រោលឃ្វង ។ ព្យុះស្ងប់ទៀបថ្ងៃត្រង់ នោះគេដើរតាមគន់ចំណាំសព្វសារពើ គេឃើញដើមឈើរកផុតពីដើម ឈើធំៗរលំរលើង ខ្លះមានឬសរបះឡើងស្ទើរតែស្មើនឹងកំពស់ដើមវិញ ។ ដើមត្នោតដេកជាប់ឬសរលំព្រគីងព្រគង់លើគ្នា ។ ចំការចេក ចំការអំពៅបាក់កប់ដូចគេផ្តួកគ្មានសល់មួយដើមឡើយ ។ ផ្លែស្វាយកយខ្លាំពេញនៅក្រោមដើម ។ ប៉ុន្តែខ្យល់ព្យុះនេះជាព្យុះអស្ចារ្យ គេហថ្លន ទាំងប៉ុន្មានសិងនៅជាប់ ទាំងខ្ទុកនាក់ធំតូចក៏ពុំមានអន្តរាយមួយសោះឡើយ ឯ-មហាជនទាំងឡាយបណ្តានៅក្នុងកំឡុងព្យុះ ក៏ពុំមានឋស់ដោយបង់ជីវិត ឬពិ-ការដោយសារព្យុះនោះឡើយ ។

---

ពន្យល់ពាក្យ.— ព្យុះ, ពាយុ, វាយុ, វាយោ, វ្យា = ខ្យល់; ខ្យល់បក់ខ្លាំងគឺព្យុះ ។ ខ្យល់រត់ក្នុងខ្លួននៃយើង ឬក្នុងអាកាសហៅវាត, វាតគុល្ម ឬចក្រវាត = ខ្យល់កំបុតត្បូង ។ ឈើរាជ ឈើចាស់តាំងពីបូរាណមក ។

# ពលីការសុំទឹកភ្លៀង

កាលពីដើមខ្ញុំបានឃើញបណ្ដាជនស្រុកស្រែ រៀបពលីសុំទឹកភ្លៀង នៅឆ្នាំណា ទឹកភ្លៀងក្រ ៗ បណ្ដាជនអ្នកដើរវត្តទៅប្រជុំគ្នាក្នុងទីអារាម រៀបពិធីបីថ្ងៃ ។ ក្នុងរបៀបពលីនោះគេជីករណ្ដៅចតុរស្សមួយ ទំហុំពីរហត្ថមួយចំអាម ជំរៅមួយហត្ថ ធ្វើកំផែងព័ទ្ធជុំវិញ ទុកទ្វារបួនឈមទៅទិសទាំងបួន មានឆត្រគ្រមួយ ៗ នៅមុំ ទិសឆត្រមួយគូ ស្វាធមិមួយគូ គ្រប់ទ្វារទាំងបួន ទិសស្វាធមិទិសបួនទៀត ។ គេសូនរូបត្រីរ៉ស់មួយដាក់ក្នុងរណ្ដៅ ឈមមុខទៅឦសាន សូនរូបទេវតាមួយអង្គឈរក្នុងស្រះឬរណ្ដៅនោះ ព្រះភក្ត្រងើយទៅលើ ឈមមុខនៅឦសាន ព្រះហស្តឆ្វេងស្ទួយព្រះអង្គ ព្រះហស្តស្តាំលាតចង្អុលទៅលើឈមឦសាន ។ គេដាក់ទឹកទៅក្នុងរណ្ដៅ ព័ទ្ធសីមាជុំវិញព្រះរាជវត្ត ហើយដាក់ក្បាច់អំពោះសីមានោះ នៅព្រះជ័រក្នុងព្រះវិហារ ។ ដំបូងគេនិមន្តព្រះសង្ឃសូត្រព្រះបរិត្តវេលាល្ងាច វេលាថ្ងៃត្រង់ទើបឧបាសកឧបាសិកា នូវទាយកទាយិកា សម្បូរនិសស្រង់ព្រមគ្នាបំពោះទៅទេវតាពលាហក សុំឲ្យបណ្ដាលទឹកភ្លៀងធ្លាក់មក រួចហើយទើបនិមន្តលោកសង្ឃបួនអង្គ ឈរជុំវិញរណ្ដៅឈមមុខទៅក្នុងស្រះនោះ រួចសូត្រធម៌ដែលមានអាទិ៍ថា ៖

សតោពន្ទោ បមហាថេរេ ..... ត្រាតែបាន ១០៨ ចប់ ទើបអស់ពិធីនាថ្ងៃដំបូង ។ ពិធីដូច្នេះជាគំរប់ ៣ ថ្ងៃ ។

10

កាលក្នុងរជ្ជព្រះបាទស៊ីសុវត្ថិ មានឆ្នាំមួយនោះក្រិតក្រៀងណាស់ សត្វពាហនដូចជាគោក្របី សេះជ្រូកមាន់ទា ស្លាប់វិនាសជាច្រើន ដោយអត់ទឹក ។ គោខ្លះស្លាប់នៅមានសុទ្ធតែភក់ក្នុងត្រពះ ឯមនុស្សម្នាមហាជនក៏ក្រស៊ប់នៅក្នុងស្រុកភូមិដោយលំបាកវេទនាពេកពន់ ទាំងអត់បាយ ទាំងអត់ទឹក ទើបគេរៀបពិធីសុំទឹកភ្លៀងគ្រប់ភូមិស្រុក ភ្លៀងក៏មានឡើងបានធ្វើការរកស៊ីជាសុខសប្បាយ ជំងឺជំកាត់ផ្សេង ៗ ក៏អន្តរធានបាត់ទៅ ។

ពន្យល់ពាក្យ.— ពលី ឬ ពលិ = ការបូជា ។ រាជវតិ = របង ; វត្ថុបទុមវតីគឺវត្ថុមានល្អួកជារបង; វត្តិ = វិលទៅមក ; ទស្សនាវត្តិ = ការឃើញទៅមុខវិញ ។— ពលាហក = ទេវតាដែលបង្ករភ្លៀង ។ — អង្គេ = បង្កេះ ។ — ព្រះដីវ៍ = ព្រះបដិមានៃព្រះរូបព្រះពុទ្ធ ។

អានិកដ្ឋាន

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ១ - អំពីពេលវេលា

នាម- ថ្ងៃ យប់ អាទិត្យ ខែ ឆ្នាំ មួយរំពេច មួយស្របក់ ម៉ោង នាទី (មីនុត) ។

គុណនាម- ភ្លឺ ងងឹត យូរ ឆាប់ ឆ្នាំចាស់ ឆ្នាំថ្មី ខែមុន ខែក្រោយ ដើមខែ ចុងខែ កណ្ដាលខែ ។

កិរិយាសព្ទ — ខាតពេលវេលា កត់ថ្ងៃ ខែ ឆ្នាំ មើលម៉ោង ថ្ងៃរះ ថ្ងៃលិច ថ្ងៃចាំង ។

ហាត់ភាសា — ដែលគេហៅថាពេលវេលានោះគឺអ្វី? ក្នុង ១ ឆ្នាំមានប៉ុន្មានខែ? គឺខែអ្វីខ្លះ? ខែនេះយើងកប់ឆ្នាំជាប៉ុន្មាន? គឺឆ្នាំអ្វីខ្លះ? ក្នុងមួយអាទិត្យមានប៉ុន្មានថ្ងៃ? គឺថ្ងៃអ្វីខ្លះ? ក្នុងមួយខែមានប៉ុន្មានថ្ងៃ? ក្នុង ១ ថ្ងៃ ១ យប់មានប៉ុន្មានម៉ោង?

## បង្រៀនមើល

### អំពីពេលតាមរបៀបខ្មែរ

( សៀវភៅវគ្គស្វាធ្យាយន៍បរិវេណដ្ឋានទំព័រ ១០៨ )

កែតម្រូវ — អាសុជ្ឈ = អស្សុជ ។ បឋមសាឍ = បឋមាសាឍ

## សរសេរតាមសូត្រ

### អំពីពេលវេលា

ដែលហៅថាពេលវេលានោះគឺ គេសម្រេចយកតាមកំណត់ដំណើរព្រះធរណីវិលជុំវិញខ្លួនឯង ហើយនិងវិលក្រឡ៊ែនជុំវិញព្រះអាទិត្យផង ។ ពេលដែលព្រះធរណីវិលបានមួយជុំខ្លួនឯងនោះ ហៅថាមួយថ្ងៃមួយយប់ គឺម្ភៃបួនម៉ោង លុះព្រះធរណីវិលបានមួយជុំព្រះអាទិត្យ ទើបហៅថាមួយឆ្នាំ មួយឆ្នាំមានបីរយហុកសិបប្រាំថ្ងៃ ឬ ហាសិបពីរអាទិត្យ ។

ដែលហៅថាផ្លូវនោះ គឺគន្លងកំឡុងដែលខ្យល់អាកាសផ្លាស់ប្ដូរនាំគ្នា មួយផ្ទាំៗ ។

សរសេរពាក្យពិបាក.— ដំណើរ ព្រះធរណី ព្រះអាទិត្យ ថ្ងៃ ហុកសិបប្រាំ ហាសិបពីរ ខ្យល់ ផ្លាស់ប្ដូរ ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីអ្នកប្រើពេលវេលាដូចម្ដេចខ្លះ តាំងពីព្រលឹមឡើង រហូតដល់ព្រលប់ ។

### ទំនងតែង

តាំងពីព្រលឹមរហូតដល់ពេលបាយ អ្នកធ្វើអ្វីខ្លះ? ចុះពេលបាយទល់ នឹងព្រលប់អ្នកធ្វើអ្វីទៀត?

## អក្សរផ្ចង់

បង្រៀនសរសេរអក្សរ "មូល"

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី ២.— អំពីខ្យល់

នាម.— ខ្យល់ ខ្យល់រំភើយ ខ្យល់ដំនោរ ខ្យល់ព្យុះ ព្យុះសង្ឃរា ខ្យល់កំបុតត្បូង (ខ្យល់គួច) ខ្យល់ពីងដើន ។

គុណនាម.— រហ័ស ត្រសៀក ត្រជាក់ ស្រា តិច ខ្លាំង រំភើ ។

កិរិយាសព្ទ.— ខ្យល់បក់តិចៗ ខ្យល់បក់ខ្លាំង ខ្យល់គួចធូលី បង្ហើរខ្លែង បើកក្ដោង ។

ក. ហាត់ភាសានិងការហាត់សរសេរ សុំគ្រូតែងធ្វើជូនសិស្ស ។

## បង្រៀនមើល

## អំពីខ្យល់បក់មកពីទិសខាងជើង

សៀវភៅវិជ្ជាខេមរភាសាបរិវច្ឆណ្ណជ្ជាន ទំព័រ ៦៤ មេរៀនទី ៤៣

## សរសេរតាមសូត្រ

## អំពីខ្យល់

កាលណាយើងឈរឬអង្គុយនៅកណ្ដាលវាលស ហាក់ដូចជាមានអ្វីមកប៉ះពាល់ខ្លួនយើងនាំឲ្យល្ហើយ នេះហៅថាខ្យល់ ។ ឯស្លឹកឈើវិលក៏រើកទៅមកផង នោះគឺខ្យល់បក់ ។ ខ្យល់បក់នេះ ជួនខ្លាំង ជួនតិច ខ្យល់បក់តិចៗហៅថាខ្យល់ជំនោរ ខ្យល់បក់ខ្លាំងហៅថាព្យុះ កាលណាខ្យល់នោះបក់ខ្លាំងអស្ចារ្យ ហៅថាព្យុះសង្ឃរា ។ ខ្យល់ព្យុះអាចធ្វើឲ្យដើមឈើ ផ្ទះសម្បែង ទូក កប៉ាល់ អន្តរាយបាន ។

ខ្យល់មានប្រយោជន៍ ដើម្បីឲ្យអ្នកជិះទូក សំពៅបើកក្ដោងលឿនទៅបានស្រួល ។

សរសេរពាក្យពិបាក.— ខ្យល់ ល្ហើយ ពល ព្យុះសង្ឃរា អន្តរាយ អស្ចារ្យ កប៉ាល់ លឿន ។

## តែងសេចក្តី

ចូរអ្នកអធិប្បាយអំពីខ្យល់ព្យុះតាមពាក្យចោទខាងក្រោមនេះ ៖

យ៉ាងដូចម្តេចដែលហៅថាខ្យល់ព្យុះ? នៅក្នុងរដូវណាដែលមានខ្យល់ព្យុះ? ខ្យល់នោះបក់មកពីទិសឯណា? មុននឹងមានខ្យល់នោះ អ្នកសំគាល់ឃើញហេតុអ្វីនៅលើមេឃ? វេលាខ្យល់នោះបក់មក អ្នកត្រូវធ្វើដូចម្តេចខ្លះ? អ្នកឃើញមានអ្វីមកជាមួយផង? អ្នកឃើញខ្យល់នោះបណ្តាលឲ្យមានហេតុអ្វីខ្លះនៅក្នុងភូមិអ្នក-នៅក្នុងវាលស្រែ? អ្នកចូលចិត្តនឹងខ្យល់នោះឬទេ? ពីព្រោះអ្វី? ។

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី ៣.— អំពីភ្លៀង—ផ្គរផ្គួ

នាម.— ភ្លៀង ផ្គរ រន្ទះ ផ្លេកបន្ទោរ ផ្គរផ្គួ សន្សើម ត្រាប់ភ្លៀង ទឹកភ្លៀង ។

គុណនាម.— ច្រើន តិច ស្រិចៗ ព្រួចៗ រលឹម ទទឹកជោក សើម ។

កិរិយាសព្ទ.— រាំងភ្លៀង ភ្លៀងស្រក់តក់ៗ ទឹកភ្លៀងដក់ ទឹកភ្លៀងជ្រាបទៅក្នុងដី ត្រងទឹកភ្លៀង ងូតទឹកភ្លៀង ។

ការហាត់ការហា និងការហាត់សរសេរ សុំគ្រូតែងធ្វើដូចសព្វដង

# អំពីនាឡិកា

នាម.— នាឡិកាយោល នាឡិការោទ៍ នាឡិកាដៃ ផ្ទះនាឡិកា គ្រឿងនាឡិកា ខ្សែលាន កូនសោ ប៉ោល ទ្រនិច លេខ កញ្ចក់ ម៉ៃ

គុណនាម.— ទៀង យឺត លឿន តាំង ខូច ដាច់លាន ថ្មី ចាស់ ។

កិរិយាសព្ទ.— មួលនាឡិកា ផ្ទៀងនាឡិកាឬម៉ោង បង្វិលទ្រនិច មើលម៉ោង នាឡិកាដើរ នាឡិកាឈប់ (ហៅថានាឡិកាងាប់) ។

១ ទៀតត្រូវសាបប្រៀនពាក្យដែលកើតអំពីឬសគល់ដូចគ្នា ពាក្យប្រើផ្ទុយគ្នា និងពាក្យផ្ទុយ ។

## សរសេរតាមសូត្រ

### អំពីភ្លៀង

ទឹកភ្លៀងបង្កើតមកអំពីពពក ឯពពកកើតឡើងអំពីចំហាយទឹកនៅវេលាដែលត្រូវកំដៅព្រះអាទិត្យ ប្រមូលផ្តុំគ្នាឡើងហើយអណ្តែតទៅលើអាកាស កាលណាពពកនោះសោតទៅប្រទះនិងខ្យល់ត្រជាក់ខ្លាំងក៏កកទៅជាទឹក ហើយធ្លាក់មកជាទឹកភ្លៀង ទឹកភ្លៀងជ្រាបទៅក្នុងដីសំរាប់ចិញ្ចឹមរុក្ខជាតិទាំងឡាយ ឬផ្តុំគ្នាកើតបានជាជហ្វើមទឹក មួយចំណែកទៀតហូរធ្លាក់ទៅក្នុងថ្លុកត្រពាំង បឹង ស្ទឹង ទន្លេ សមុទ្រ ។ កាលណាមានភ្លៀងច្រើនមានព្យុះ ផ្គរ ផ្លេកបន្ទោរហើយនិងរន្ទះផង ។

ពាក្យពិបាក. — ផ្ដុំ អណ្ដែត សោក រុក្ខជាតិ ព្យុះ ផ្គរ ផ្គួចផ្ដោរ ។ ភ្លៀងស៊ររសោរ បាចពីយ៉ាន ភ្លៀងឬផ្លៀង ។

## តែងសេចក្ដី

១ — ចូរអធិប្បាយអំពីភ្លៀងតាមពាក្យចោទខាងក្រោមនេះ ៖ នៅស្រុកខ្មែរយើង រដូវណាដែលមានភ្លៀងច្រើន? ភ្លៀងនោះធ្លាក់មកពីណា? វេលាមុនភ្លៀងអ្នកឃើញមានអ្វី ហើយអ្នកឮសូរអ្វី នៅលើមេឃ? នៅវេលានោះមេឃយ៉ាងដូចម្ដេច? លុះបន្តិចមកទៀតអ្នកឃើញមានអ្វីស្រក់ចុះមក ហើយហូរធ្លាក់ទៅឯណា? នៅក្នុងស្រែឬក្នុងថ្លុកត្រពាំងអ្នកឃើញមានអ្វី? នៅក្នុងរដូវនោះអ្នកស្រែចំការធ្វើអ្វីខ្លះ? ឯទឹកទន្លេឡើងឬស្រក? អ្នកចូលចិត្តទឹកភ្លៀងឬទេ? ពីព្រោះអ្វី?

២ — ចូរអ្នកអធិប្បាយអំពីនាឡិកាដក់ តាមពាក្យចោទខាងក្រោមនេះ ៖ អ្នកមាននាឡិកាដក់ឬទេ? នាឡិកានោះធ្វើអំពីអ្វី? រាងវាយ៉ាងដូចម្ដេច? នៅខាងមុខវាអ្នកឃើញមានអ្វីខ្លះ? ឯក្រវិលនិងកំពូលប្រើសំរាប់ធ្វើអ្វី? ឯទ្រនិចវាទាំងពីរប៉ុនគ្នាឬទេ ហើយវិលស្មើគ្នាឬទេ? ទ្រនិចមួយចង្អុលអ្វី? ទ្រនិចមួយទៀតចង្អុលអ្វី? បើអ្នកយកនាឡិកាដក់មកដាក់ជិតត្រចៀកអ្នកឮសូរដូចម្ដេច? អ្នកស្រឡាញ់នាឡិកាអ្នកឬទេ? ពីព្រោះអ្វី?

# ១– តែងសេចក្ដីជាគំរូ

ចូរអ្នកអធិប្បាយអំពីថ្ងៃមួយដែលមានភ្លៀងមួយមេយ៉ាងធំ ។ អ្នកបានឃើញដូចម្ដេចខ្លះ នៅវេលាមុនភ្លៀង វេលាកំពុងភ្លៀង វេលាក្រោយភ្លៀង? យោបល់យល់ឃើញរបស់អ្នក? ។

## សេចក្ដីអធិប្បាយជាគំរូ

កាលពីថ្ងៃ ២៣ ខែឧសភា គ. ស. ១៩៥០ នៅក្រុងភ្នំពេញមានភ្លៀងមួយមេយ៉ាងធំ មុននឹងភ្លៀងនោះ ខ្ញុំឃើញមេឃងងឹតផ្លេកបន្ទោរព្រាតៗ ផ្គរលាន់ផ្ទុំៗទិស បានបន្តិចមានខ្យល់បក់មកយ៉ាងខ្លាំង ហើយមានទាំងតំណក់ទឹកធ្លាក់មកជាមួយផង ។

ឯស្លឹកឈើដោយត្រូវទម្ងន់ទឹកភ្លៀងធ្លាក់មកជាប់នោះ ក៏ទន់ទោរសំយ៉ុងចុះមកក្រោម តែវេលាណាខ្យល់បក់មក តំណក់ទឹកនោះហូរស្រក់តក់ៗដូចជាធារនៃទឹកក្នុកមុខគួរឲ្យស្ងើចណាស់ ។ ឯដីទំនាបលិចអស់ឃើញសុទ្ធតែទឹក នៅលើផ្លូវទាំងអស់លើកតែថ្នល់ដែលចាក់កៅស៊ូចេញ ក៏បែកកក់ស្អុតដូចជាបាយម៉ានដែលអាចធ្វើឲ្យជាប់បាតស្បែកជើង អ្នកធ្វើដំណើរទាំងប៉ុន្មានដើរបានតែលបៗ ហើយឱនក្បាលកោងខ្នងបន្តិចផង ព្រោះប្រុងប្រយ័ត្នកុំឲ្យល្អិលប្អូស្អិតជាប់ជើងបាន ។ រីឯបឹងទឹមសេះ គ្រប់ក្រយាន រថយន្ត សុទ្ធតែបើកប្លុកលើកដំបូល ក៏ប៉ុន្តែវេលាណាខ្យល់បក់មកខ្លាំងទឹកភ្លៀងក៏បាចសាចចូលទៅពេញ

ផលែផល ។ កង្វះពេលនោះមិនសប្បាយទេ ព្រោះមនុស្សសត្វជាប់នៅតែក្នុងផ្ទះ ឬក្នុងម្លប់ ចេញទៅណាមកណាមិនរួចអារម្មណ៍ក្រង់តែទទឹកនឹងទឹកភ្លៀង ៗ ពេលនោះជាពេលនាំឲ្យលំបាកចិត្តណាស់ ៗ ដោយហេតុល្អប្រហែលជា ម៉ោងព្រឹកខ្ទុះ នៅលើមេឃឃើញមានពន្លឺព្រះអាទិត្យលេចបន្តិច ៗ ឡើង ឯភាពកក់ក្តៅនៃភពត់បន្តិចម្តងៗទៅ គឺដឹងថាពេលល្អជួបធម្មតានោះត្រឡប់មកវិញហើយ មនុស្សនិងសត្វទាំងឡាយក៏បានសេចក្តីរីករាយ ដូចពេលធម្មតាឡើងវិញដែរ ។

ខ្ញុំបានយល់ឃើញថា ទឹកភ្លៀងមានប្រយោជន៍ដល់មនុស្សសត្វជាទីបំផុត ប៉ុន្តែបើភ្លៀងច្រើនហួសប្រមាណនឹងនាំឲ្យរំខាន ឬខូចខាតផលប្រយោជន៍ទៅវិញក៏សឹងមានដែរ ។ ០៩–

## មេសូត្រត់មាត់

### ទន្លេមេគង្គ

ទន្លេមេគង្គនេះគឺជា ផលៈធាតុធំដល់ទី ហូរពាក់ធ្លាក់ចុះមកអំពី គីរីស្រុកចិនឈ្មោះទីបេ ។ វែងជាងបួនពាន់គីឡូម៉ែត្រ កាត់ខេត្តទិសម្តុំឈប់ទេ បណ្តាលទៅភាគាខេត្ត នឹមេទិកមួយកាត់ស្រុកយើង ។ ប្រមាំលស៊ីងអូរឯ វៀតព្រោះ ព្រំនៃជ្រោយចន្ទោះជ្រោះទៅជើង ក្នុងពួកតាមទំនើង រលើង ធ្លាក់ចុះដល់ទីល្បាក់ ៗ ពេលទឹកជំនន់ទន្លេនោះ ជន់បែកគគុះធ្លុះធ្លាយធ្លាក់

ហូរនាំល្បប់ដីយកមកដាក់ នៅពាក់ឡើយកើតកោះសម្បត្តិ ។ ហើយបណ្ដាលដុះ ពសុធា គជាស្រុកទេសប្រទេសស្អាត ទន្ទង់ដោយហូរហ្វាយធ្លាក់ ស្រោតទៅ ធ្លាក់ក្នុងសមុទ្រ ។

---

ពន្យល់ពាក្យ. — ផលធារា — "ម. បិ. ផៈលៈធារា" ន. ខ្សែទឹក, ផ្លូវទឹក ។

ល្បាក់ — ន. ថ្នាក់ដែលធ្លាក់របេះ ឬដែលមានសណ្ឋានដូច ជាធ្លាក់ : ល្បាក់ច្រាំងទន្លេ ។

ពសុធា — ន. ផែនដី; ពីភពលោក "ប. គ"

## រឿងមើលកំសាន្ត

### ឆ្មានឹងកណ្ដុរចាស់ (គតិខេឧសភា)

ពេលនោះកណ្ដុរ ចាស់មួយត្រសុល ត្បូលចូលមកជិត ឃើញពួក ខ្មាំងឆ្មាប់ កប់ហោងដោយបុណ្យ ដែលបម្រើមិត្ត ស្គាល់ពិតជាធ្នា ។ "ទើបពោលថា អើ! អាឯងត្រានបើ បេះបើប្រាជ្ញា បន្ទំធ្មេញម្ល៉េះ ផងរឹតទៅធ្នា អញស្គាល់ វិគ្គា អស់ហើយកុំលាក់ ។ កាលអញកម្លោះ មិនឯងលោតផ្លោះ មកក្លាយ ត្រប់ពាក់ កន្ទុយអញជាប់ សាច់ឈាមស្រោក អញនៅចាំជាក់ ចាប់លាក់ មុខថ្មី ? ។ បើទុកជាដុំ ម្សៅនោះហ៊ានធំ ប៉ុនក្ដុំផងក្ដី ចាំងឈ្មោយចាំងទាញ កអញមិនខ្វី សុំទេចំណី នេះស្បែងខ្លាំងណាស់ ។ មិនបោកគូនកូន ទំពា ស៊ីលេង ហ៊ានហ្វឹងបោះ ពីព្រោះគ្មានព្រៀប ទើបអង្វរការណាស់ ហ៊ាន អញក្បាលចាស់ បោកប្រាស់ម្ដេចឆ្មាយ ?» ។

គួរសរសើរណាស់ ពាក្យគណ្ឋាចាស់ នេះបេះនិយាយ បេះការស្រែក មិនសូវពាយអាយ ចិត្តឥតពាយមាយ បេះទាយទោសខ្លួន ។ ស្គាល់ផ្លូវកុំឆាប់ ស្គាល់ផ្លូវរស់ស្លាប់ ស្គាល់ផ្លូវកំរេច ស្គាល់ផ្លូវចំពោក ស្គាល់ផ្លូវក្រឡិច មិនដែលភ្លាំងភ្លេច សេចក្ដីលែកង ៗ រូបដកពិត តែត្រង់ធំនិត រឹងរឹតវែកង ពោះក្រុងជំទង់ ក៏គង់មិនជាង គួរកុំរំលង ពាក្យចាស់ពោលអើយ ។

(ប.គ.)

---

## រាត្រីខែភ្លឺ

ក្រោយពេលសុរិយង្គអស្តង្គត លិចផុតចំនួនមួយម៉ោងទៅ
ព្រះច័ន្ទ្រចាំងចែងសែងសន្ធៅ នៅលើចុងព្រឹក្សព្រៃទាំងឡាយ ។
រាតផាត់សោត់គន្ធុំ វនកុសុមក្រអូបសាយ
ពេលក្លិនមកមុនរំភើយឆ្ងាយ ក្លាយជាស្តើមហិមវ័ង្សី ។
អឌ្ឍរាត្រីកាល ភ្លឺប្រាលបំបូងក្នុងរាត្រី
លេចឡើងសន្សឹមលឿងទឹមទ្វី បញ្ចាំងរស្មីពេញផ្ទៃមេឃ ។
ផ្លូវណាៈស្តួចយាងតាមមាគ៌ា ក្នុងផ្ទៃនភាភ្លឺអនេក
ផ្លូវណាផ្កាកក្នុងស្រែទាប់មេឃ ពពកជៀតជែ ពាសបំពាំង ។
សភាពដូចភ្នំធំពន្លឹក មានទឹកកកជាប់នៅទាំងផ្ទាំង
ប្រិតប្រេបប្រិតខ្ចប់បិទបាំង បីដូចរនាំងបាំងលំអ ។

---

**ពន្យល់ពាក្យ.—** **សុរិយង្គ** — ន. "ព្រះអាទិត្យ"

**អស្តង្គត** — កិ. ឬ គុ. ព្រះអាទិត្យលិច

**គន្ធ** — (ម. ចិ. គន់ធ) ន. ក្លិន

**ធុំ** — កិ. ធុំក្រអូប

<u>ប្រឋាប់</u> – កិ. ឈប់, ឈរ, អង្គុយ

<u>វនកុសុម</u> – (ម. ថ. វនៈ កុសុម ) ន. ផ្កាព្រៃ ។

<u>ហិមរំស្សី</u> – (ម. ថ. ហិមៈ រំស្សី ) ន. ព្រះច័ន្ទ ។

<u>អគ្គនារី</u> – ន. ឬ គុ. ស្ត្រីខ្ពស់បំផុត ស្តេចស្រី ។

<u>រត្តិកាល</u> – ន. ពេលយប់

<u>នភា</u> – ( ម. ថ. នៈភ ) ន. ពពក, មេឃ

( ប. ត. )

# រាត្រីខែភ្លឺ (ត)

វិការដ្ឋានលើភូមិភព
ណាស់ដែរសូម្បីតែល្អាងថ្ម
ប្រឋាប់សម្រាកកាយសម្រាន្ត
ផតកំរើកអង្គផ្ចង់អារម្មណ៍
រុក្ខជ្ជាយាធ្នុះចេញស្មោះ
អណ្តែតត្រសែតទៅតាមភគ
ក្រៅពីសូរស្លឹកឈើធ្លាក់មក
នៅមានសម្លេងសត្វបក្សី
ក្នុងមជ្ឈិមយាមយប់ស្ងប់ស្ងាត់
ជាទីរីករាយក្រៃកន្លង

ប្រារភឲ្យឃើញផែនដីល្អ
ក៏ឃើញព្រះច័ន្ទនិទ្រារម្មណ៍ ។
នៅក្នុងស្មសានហើយក៏ផ្ទុំ
សំងំក្នុងគុម្ពតិណជាតិ ។
មីដូចភាពកោះស្តុងៗព្រាត
ហាក់ជាតុឧយះផ្ញើករស្មី ។
និងសូរខ្យល់បោកក្នុងរាត្រី
ហួងរាត្រីបរយំម្តងៗ ។
ត្រជាក់ពេកក្តាត់ឥតសៅហ្មង
ទាំងផែនភពផងសិងសប្បាយ ។

ពន្យល់ពាក្យ. –

<u>វិការដ្ឋាន</u> – ន. កន្លែងដែលមានហេតុកើត ។

<u>ប្រារភ</u> – កិ. តាំងផ្តើម, ផ្តួចផ្តើម ។

<u>ល្អាង</u> – ន. អណ្តូងឬថ្មុកថ្ម កើតឯងនៅភ្នំ ។

<u>និទ្រារម្មណ៍</u> – ន. ដំណើរដេកលក់ ។

អារម្មណ៍ — ន. ការដឹង,...

គិណជាតិ — ន. ស្មៅ

រុក្ខជាយា — ន. ស្រមោលម្លប់ឈើ ។

ភិត — ន. ខ្យល់ ។

ធាតុឧយៈ — ន. ធាតុទឹកសមុទ្រ ។

ភត្រ៊ិបរ — គុ. ឬនាម; មៀម, ទំទុយ,

ខ្វែងស្រាក ។ ល ។ (ប. គ.)

## គ្រូពេទ្យនឹងលាញី

លោកគ្រូពេទ្យម្នាក់ជិះលាញី ដើម្បីទៅទីមនុស្សជម្ងឺ
មួយដែលកំពុងតែដេកឈឺ គឺកកើតពិសរោគខាន់ស្លាក់ ។
ពេលពេទ្យដល់ផ្ទះជម្ងឺនោះ ក៏ចុះពីលាទៅភក់ទាក់
នឹងមនុស្សស្គាល់គ្នាជាមិត្តភក្តិ នៅទ្វារផ្ទះអ្នកដែលកើតរោគ ។
មេលាគ្រៀងគ្រប់សម្រាប់ជិះ ដែលជាជំនិះរបស់លោក
ចូលតាមទ្វារផ្ទះដើរទៅឈ្លោក មើលអ្នកមានរោគកំពុងដេក ។
អ្នកឈឺឮស្វរជើងមកជិត គិតស្មានថាៈពេទ្យនឹកអពេក
ហុចដៃឲ្យគ្រូគមិនក្រឡេក ងាកភ្នែកមើលក្រោយដោយទុកចិត្ត ។
លាញីឃើញដៃមកចំមុខ យកមាត់ជញ្ជក់ពាំខាំស្អិត
អ្នកឈឺងាកមកឃើញលាលិទ្ធ ភ័យភិតបុះពីគ្រែធំណោក ។

ពន្យល់ពាក្យ.— ខាន់ស្លាក់.— ន. ឈ្មោះរោគមួយយ៉ាងកើតកណ្តាលក ធ្វើឲ្យលេមបាយ-ទឹកពុំរួច ។

ភក់ទាក់—កិ.វិ.ឬ គុ. ដែលពោលស្រុះស្រួល ទទួលដោយអើពើ, ចៅរើ ។

មិត្តភក្តិ—ន. សេចក្តីស្មោះត្រង់ចំពោះមិត្ត ។

# គ្រូពេទ្យនិងលាញី (ត)

ទើបដេញលាចេញដោយទោមនស្ស ហើយអស់សំណើចសើចខ្លាំងពេក
ពិសក្នុងបំពង់កនោះបែក អ្នកឈឺនឹកត្រេកអរផុតបី ។
ពេទ្យចូលមកទាត់គិតនឹងវាត់ លានឹងរំពាត់វែងខ្សែតី
តែអ្នកជម្ងឺឃាត់ហាមខ្មី ថា : « សូមប្រណីកុំវាយវា ។
គួរឲ្យអស្ចារ្យណាស់លាលោក បេះមកមើលរោគខ្ញុំឲ្យជា
លោកបានព្យាយាមមើលរោគា ខ្ញុំយូរវេលាពុំជាសោះ ។
តាំងពីថ្ងៃនេះទៅមុខលោក បើរោគខ្ញុំរើឈឺទៀតហ្នោះ
កុំព្រួយអញ្ជើញមកឲ្យសោះ ឲ្យតែលានោះមកបានហើយ » ។

---

ពន្យល់ពាក្យ.–

វាត់ – កិ. វាត់នឹងរំពាត់

ទោមនស្ស – ន. សេចក្ដីតូចចិត្ត–អាក់អន់ចិត្ត ។

ព្យាយាម – ន. ការប្រឹងប្រែង ។

បដ្ឋមដ្ឋានទី ១

## នព្វន្ត

*លេខចែកជំនួសអនិយមភាគ សារៀនអំពីលេខទាំង៤យ៉ាង ចំណោទក្នុង លេខទាំង៤យ៉ាង ជំនួសគត់និងទសភាគ សារៀនហាត់គិតលេខដោយបញ្ញា ចេកជំនួនទីន ០,៩០, ទីន ០,២៥ ។*

# អាទិត្យទី១— អំពីលេខចែកជំនួនអនិយមភាគ

ឧទាហរណ៍ មនុស្សម្នាក់ស៊ីឈ្នួលធ្វើការ ក្នុង១អាទិត្យ ៣៩ ម៉ោង តើអ្នកនោះធ្វើការក្នុង ១ ថ្ងៃប៉ុន្មានម៉ោង បើអ្នកនោះឈប់ពល់តែថ្ងៃអាទិត្យ ។

របៀបពន្យល់: អ្នកនោះធ្វើការក្នុង ១ អាទិត្យប៉ុន្មានថ្ងៃ ។ ក្នុង៦ថ្ងៃអ្នកនោះធ្វើប៉ុន្មានម៉ោង ។ ចុះបើក្នុង ១ ថ្ងៃវិញ តើអ្នកនោះធ្វើការតិចជាងឬច្រើនជាង៦ថ្ងៃ ។ តិចជាងប៉ុន្មានដង ។

របៀបធ្វើលេខ: ៣៦ម៉:៦:= ក្នុង ៣៦ មាន ៦ ប្រាំមួយដង

| | |
|---|---|
| ៣៦ម | ៦ |
| ៣ | ៦, ៣០ |
| + ៦០ | |
| ១៨០ ម.ន | |

៦ × ៦ = ៣៦ម ។ យកទៅកាត់នឹង ៣៩ សល់ ៣ ម៉ោង ។ នេះចែកនឹង៦មិនបាន ត្រូវបំលែងទៅជាមីនុត ១ម៉ = ៦០មន × ៣ = ១៨០ មន ក្នុង ១៨០ មីនុតមាន ៦ សាមសិបដង ៦មន × ៣០ = ១៨០មន ។ យកទៅកាត់នឹង ១៨០ គ្មានសល់អ្វីទេ ។ ឆ្លើយថា អ្នកនោះធ្វើការក្នុង១ថ្ងៃ ៦ ម៉ោងនិង ៣០ មីនុត ។

បើចង់ផ្ទៀងផ្ទាត់ឲ្យឃើញខុសត្រូវ ឲ្យគុណកំណត់ពេលដែលធ្វើការក្នុង១ថ្ងៃនិង៦ថ្ងៃ នឹងឃើញកំណត់ពេលដែលធ្វើការក្នុង៦ថ្ងៃគឺ ៣៩ម៉ ។

សេចក្តីរំលឹក: កាលណាចំនួនសេស តូចជាងដែនហារនិងចែកមិនបាន ត្រូវបំបែកចំនួនសេសនេះឲ្យតូចទៅ គឺបំបែកម៉ោងទៅជាមីនុត ៗ ទៅជានាទី (គុណចំនួនសេសនឹង៦០)

បើលេខដំណាំងមានចំនួនមីនុតផង ត្រូវយកចំនួនដែលចែកឃើញនោះ ទៅបូករួមនិងចំនួនមីនុតនោះ ។

ឧបមា:

```
១៣ម៉ ២៥ | ៥
        |-----
៣       | ២,៤១
+ ៦០ម.ន
------
១៨០ + ២៥
 ⏟
២០៥ ម.ន
 ០៥
  ០
```

ការហាត់បញ្ញាក់: ឲ្យធ្វើឲ្យបានច្រើនទៅលើក្ដារខៀន ១២$^{ម}$ : ៣ ។ ២១$^{ម}$,១៤ : ៧ ។ ៣២$^{ម}$,៤០ : ៧ ។ ៤៨$^{ម}$,៣៦$^{ម.ន}$,២៩$^{ន}$ : ១២ ។

ការហាត់សរសេរ: ភ្នាក់ងាររាជការម្នាក់ធ្វើការក្នុង១ថ្ងៃ ៥$^{ម}$,៣០$^{មន}$, លុះធ្វើបាន ២៦ ថ្ងៃ បើកបៀវត្សបាន ៤.០៦៧ រៀល តើអ្នកនោះបានឈ្នួលក្នុង ១ ម៉ោងប៉ុន្មានរៀល ។

## អាទិត្យទី ២– មេរៀនអំពីលេខបូកចំនួនទសភាគ

ការគិតលេខដោយបញ្ញា: ឲ្យសិស្សគិតគូរឲ្យបានច្រើនតាមវិធានេះ

៧$^{ត}$ + ៤ = ៦$^{ត}$,៧ + ០$^{ត}$,០៩ = ៥$^{ម}$,៩៣ + ០$^{ម}$,០៧ = ០$^{គក្រ}$៨២ + ៣,១៨ =

បំណោទងាយៗគិតមាត់ទទេ: សិស្សម្នាក់ទិញសៀវភៅសរសេរ ១ ថ្លៃ៣$^{រ}$,៥០ ខ្មៅដៃ១ថ្លៃ ១$^{រ}$,៣៧ តើគាត់ចំណាយអស់ប៉ុន្មាន ។

គេកាត់ខ្សែ១កំណាត់ប្រវែង ៧ម,៣៩ យកមកកាត់មួយកំណាត់ទៀត ប្រវែង ៤ម,៦៣ តើខ្សែដែលគេត្រូវប្រវែងប៉ុន្មាន ?

ការហាត់លើក្តារខៀនៈ សុំលោកគ្រូគិតលេខជំនួសដាក់ឲ្យសិស្សបូកចុះ

ការហាត់សរសេរៈ សុំជ្រើសរើសរកបំណោទដាក់ឲ្យធ្វើផងចុះ

សារៀនលេខបូកជំនួនអនិយមភាគៈ ឲ្យសិស្សបូកជំនួននេះឲ្យបាន ប្រើនដោយបញ្ញា និងនៅលើក្តារខៀន ព្រមទាំងបំណោទផងៗ

ការហាត់សរសេរៈ ក្នុង១ពេលល្ងាច សិស្សម្នាក់រៀនមេទន្ទេញអស់ ០ម,៤៧ម.ន ធ្វើកិច្ចការអស់ ១ម,៣៥ម.ន ហើយមើលសៀវភៅអស់ ២ម,១៥ម.ន តើសិស្សនោះរវល់អស់ប៉ុន្មានម៉ោង ក្នុង១ពេលនោះ ?

## អាទិត្យទី៣– សារៀនអំពីលេខសងជំនួនទសភាគ

លេខសងជំនួនអនិយមភាគ

សុំមើលរបៀបបង្រៀនលេខបូកជំនួនទសភាគ

## អាទិត្យទី៤– សារៀនអំពីលេខគុណជំនួនទសភាគនិងអនិយមភាគ

# រង្វាស់រង្វាល់

## អាទិត្យទី ១– សារៀនអំពីម៉ែត្រ និងខ្នាតប្រវែងរបស់ខ្មែរ

ដូចបានជំរាបមុនមកស្រាប់ហើយ និងបង្រៀនវិជ្ជារង្វាស់រង្វាល់ឲ្យបាន

ប្រយោជន៍ លោកគ្រូត្រូវតែគិតលៃលក រកឲ្យបានតែបានរង្វាស់រង្វាល់ក្នុង ទម្ងន់ទទឹងរង្វង់វត្ថុគ្រប់យ៉ាង មកឲ្យសិស្សស្គាល់ ហើយចេះប្រើប្រាស់ឲ្យ ចិតយ៉ាងមុតមាំ គឺវាស់ វាល់ ថ្លឹង ទិញដូរដោះដើម ។

ទឹងបង្រៀនខ្នាតប្រវែង ត្រូវរក ម៉ែត្រឈើបត់ ម៉ែត្របន្ទាត់ ម៉ែត្រសំពត់ ម៉ែត្រដែក ស្ទាត់ កន្លះម៉ែត្រ ពីរម៉ែត្រ ដេស៊ីម៉ែត្រ ឌូប្លដេស៊ីម៉ែត្រ ហត្ថ ខ្នាតហ្វូន ។

របៀបបង្រៀនៈ ឲ្យហាត់ប្រមាណរួចវាស់បញ្ជាក់ ប្រវែងវត្ថុដែលវែងជាងខ្នាតប្រដាប់ ដែលខ្លីជាងម៉ែត្រ វត្ថុដែលវែងជាងហត្ថ ដែលខ្លីជាងហត្ថ រួចឲ្យបំបែកជាដេកាម៉ែត្រ ជាហិចតូម៉ែត្រ ជាគីឡូម៉ែត្រ ជាដេស៊ីម៉ែត្រ ជាសង់ទីម៉ែត្រ ជាមីលីម៉ែត្រ រួចឲ្យគិតផ្ទុយពីនោះទៅវិញ ។ ឯរបៀបបង្រៀនខ្នាតខ្មែរក៏ធ្វើដូចគ្នា ។

ការហាត់គិតគូរឲ្យប្រឹកនឹងបញ្ហា ឬនៅលើក្ដារខៀនៈ ឲ្យធ្វើឲ្យបានច្រើនក្ដី ១.៣៧៥ ម៉ែត្រ មានប៉ុន្មានគីឡូម៉ែត្រ ។ ប៉ុន្មានហិចតូម៉ែត្រ ។ ប៉ុន្មានដេកាម៉ែត្រ ។ ៣៦៩ ដេស៊ីម៉ែត្រ មានប៉ុន្មានម៉ែត្រ ។ ប៉ុន្មានសង់ទីម៉ែត្រ ។ល។

១៨ ម៉ែត្រត្រូវជាប៉ុន្មានហត្ថ ។ ៧៤ ហត្ថមានប៉ុន្មានម៉ែត្រ ។ ១ ហត្ថ ១/២ មានប៉ុន្មានចំអាម ។ ២៤ ចំអាមត្រូវជាប៉ុន្មានហត្ថ ។ល។

ការហាត់សរសេរ– សុំលោកគ្រូជ្រើសរើសកិច្ចការដាក់ឲ្យសិស្ស ធ្វើផងចុះ ។

## អាទិត្យទី ២– សារៀនអំពីលីត្រ

របស់ដែលត្រូវយកមកបង្រៀនៈ លីត្រគ្រប់យ៉ាង ឈើ ថែក ស្ពាន់ រង្វាល់ដែលធំជាងរង្វាល់ប្រមាណ រង្វាល់ដែលតូចជាងលីត្រ ផ្ទាំងគំនូរ មានរូបរង្វាល់គ្រប់យ៉ាង ថាំង តៅ កណ្ដាំង ទឹកមួយក្អម អង្ករមួយពំនូក ប៉ោតទទេ ។

របៀបបង្រៀនៈ សុំធ្វើដូចកាលបង្រៀនខ្នាតប្រវែង គឺឲ្យសិស្ស ប្រមាណចំណុះវត្ថុផ្សេងៗ ដូចជាក្អម ប៉ោត ល្អី ។ល។ ហើយឲ្យ វាល់បញ្ជាក់មើល រួចឲ្យបំបែកទៅជារង្វាល់ដែលធំជាងលីត្រដែលតូចជាង លីត្រ ឲ្យគិតទៅជាតៅ ជាថាំង ជាកណ្ដាំង រួចឲ្យគិតផ្ទុយអំពីនោះ ទៅវិញ ។

ការហាត់គិតតឡប្បិកៈ សុំឲ្យធ្វើដូចកាលបង្រៀនខ្នាតប្រវែង ។

ការហាត់សរសេរៈ សុំជ្រើសរើសកិច្ចការដាក់ឲ្យធ្វើផងចុះ ។

## អាទិត្យទី ៣– សារៀនអំពីក្រាមនិងកូនទម្ងន់

របស់ដែលត្រូវយកមកបង្រៀនៈ ជញ្ជីងដែលមានថាសស្ពាន់ពីរ ជញ្ជីងមាសដែលមានថាសព្យួរ ជញ្ជីងត្រាជូរបស់វិទូ កូនទម្ងន់ដែល

ស្រោលជាន់ក្រោម កូនទម្ងន់ស្ពាន់ កូនទម្ងន់ដែក ៦ ជ្រុង និង ៤ ជ្រុង ។

របៀបបង្រៀន: សុំធ្វើដូចមុនៗ ឲ្យប្រមាណទម្ងន់វត្ថុនិងប៉ុនបញ្ជាក់ រួចសិស្សបំបែកទៅជាទម្ងន់ធុនជាងទម្ងន់ប្រមាណ ស្រោលជាន់ក្រោម ទើបគិតតាមទម្ងន់ខ្មែរ ។

ការហាត់គិតឧប្បត្តិកៈ សុំជ្រើសរើសឲ្យធ្វើជនចុះ ។

## អាទិត្យទី ៤– មេរៀនអំពីបរិវត្ត

របស់ដែលត្រូវយកមកបង្រៀន: សាច់ប្រាក់ ១ រៀល ក្រដាសប្រាក់ ១ រៀល (គប់យ៉ាងជាន់ចាស់និងថ្មី) ក្រដាស ៥ រៀល (ចាស់និងថ្មី) ក្រដាស ២០ រៀល (ចាស់និងថ្មី) ក្រដាស ៥០ រៀល ក្រដាស ១០០ រៀល (ចាស់និងថ្មី) ប្រាក់ ០,៥០ ០,២០ ០,១០ ក្រដាស ០,៥០ ០,២០ ០,១០ លុយ ៥ សេន ២ សេន ១ សេន ។ ផ្ទាំងគំនូរមានរូបបិយវត្ថុប្រាក់និងសេស ។

របៀបបង្រៀន: ឲ្យសិស្សហាត់ដូររូបិយវត្ថុពីធំទៅតូច ពីតូចទៅធំ រួចឲ្យដូររូបិយវត្ថុណាមួយទៅជារូបិយវត្ថុប្រាក់និងហើយដូរពីនោះ ឲ្យទិញដូរវត្ថុផ្សេងហើយថែមថយរូបិយវត្ថុ ។

## ធរណីមាណសាស្ត្រ

## អាទិត្យទី ១ .– មេរៀនអំពីផ្ទៃ ៤ ជ្រុងស្មើ

របៀបបង្រៀន.— ពោលសួរអំពីន័យនៃផ្ទៃ ៤ ជ្រុងស្មើ ។ ទិនគេ ផ្ទៃកន្លះ ៤ ជ្រុងស្មើ ត្រូវធ្វើរូបរម្ដបខ្លះ ។ ទិនគិតគេពាក់កណ្ដាលបរិវេណ ។ ទិនគេបរិវេណទាំងមូល ។

ការហាត់គិតគូរដោយបញ្ញា ឬនៅលើក្ដារខ្មួន: សុំឲ្យធ្វើឲ្យបានច្រើន ស្រែមួយរាង ៤ ជ្រុងស្មើ ១ ជ្រុងប្រវែង ៧ ម៉ែត្រ តើពាក់កណ្ដាលបរិវេណ ស្រែនោះទំហំប៉ុន្មាន ។ បរិវេណទាំងមូលទំហំប៉ុន្មាន ។ ស្រែនោះទំហំប៉ុន្មានម៉ែត្រក្រឡា ។

អ្នកចំការម្នាក់ទិញដី ១ ក្បាលរាង ៤ ជ្រុងស្មើ ១ ជ្រុងប្រវែង ៣៦ ម៉ែត្រ ថ្លៃក្នុង ១ ម៉ែត្រក្រឡា ៨៧៛៥០ តើអ្នកនោះចំណាយអស់ប៉ុន្មាន ។

ការហាត់សរសេរ.— គេទិញដីរាង ៤ ជ្រុងស្មើ ១ កន្លែង ១ ជ្រុងប្រវែង ៥៨ ម៉ែត្រ ៥០ ថ្លៃក្នុង ១ ម៉ែត្រក្រឡា ៥៩៛៣៥ ហើយគេធ្វើរបងព័ទ្ធជុំវិញ គិតៈទៅក្នុង ១ ម៉ែត្រ.អស់ ២៣៛២៥ តើអ្នកចំណាយទាំងអស់អស់ប៉ុន្មាន ។

## អាទិត្យទី ២.— សារៀនអំពីផ្ទៃ ៤ ជ្រុងទ្រវែង

របៀបបង្រៀន.— ធ្វើរូបតាលបង្រៀនផ្ទៃ ៤ ជ្រុងស្មើ. ពោលសួរឲ្យគេន័យ ពាក់កណ្ដាលបរិវេណ បរិវេណទាំងមូល ផ្ទៃក្រឡា ។

កាលៈណាគេដឹងបរិវេណ ហើយទទឹងបណ្ដោយ គេធ្វើរូបរម្ដបទទឹងឲ្យឃើញទទឹង ។ គេដឹងបរិវេណនិងទទឹង ត្រូវធ្វើរូបរម្ដបឲ្យឃើញបណ្ដោយ ។

បើចង់ឲ្យឃើញបណ្ដោយ ហើយដឹងផ្ទៃនិងទទឹង គេត្រូវធ្វើដូចម្ដេច ។ ធ្វើដូចម្ដេចឲ្យឃើញទទឹង បើដឹងផ្ទៃនិងបណ្ដោយ ។ល។

ការហាត់ដោយបញ្ញានឹងនៅលើក្ដារខ្មៀន : សុំជ្រើសរើសកិច្ចការឲ្យហាត់គិតគូរដូចរបៀបបង្រៀនផ្ទៃ ៤ ជ្រុងស្មើ ។

ការហាត់សរសេរ : សុំលោកគ្រូលៃលកជ្រើសរើសកិច្ចការដាក់ឲ្យធ្វើផងចុះ ។

## អាទិត្យទី ៣ .— សារៀនអំពីត្រីកោណ

របៀបបង្រៀន.— ទោះសួរដូចកាលបង្រៀនផ្ទៃ ៤ ជ្រុងស្មើ ផ្ទៃ ៤ ជ្រុងទ្រវែង ឲ្យរកន័យ រកបរិវេណ ។

ត្រីកោណមានប៉ុន្មានយ៉ាង ។ អ្វីខ្លះ ។ និងរកបរិវេណត្រីកោណស្មើជ្រុងតែ ២ ធ្វើដូចម្ដេចខ្លះ ។ ត្រីកោណស្មើជ្រុង ។ ត្រីកោណឥតស្មើជ្រុង ។ ត្រីកោណស្មើជ្រុងទាំង ៣ ។ ធ្វើដូចម្ដេចនឹងរកក្រឡាផ្ទៃត្រីកោណ នឹងរកបាត ។ នឹងរកកំពស់ ។

កាហាត់គិតគូរដោយបញ្ញា ឬ លើក្ដារខ្មៀន : សុំធ្វើដូចមុនៗ

ការហាត់សរសេរ : សុំលោកគ្រូលៃលកជ្រើសរើសរកកិច្ចការដាក់ឲ្យធ្វើផងចុះ ។

# អាទិត្យទី ៤.– សារៀនអំពីវណ្ណមណ្ឌល់និងផ្ទៃរង្វង់

របៀបបង្រៀន : សុំសាកសួរដូចពីកាលជាន់មុន ។ ឲ្យកេន័យខ្នាតវណ្ណមណ្ឌល់ (បន្ទាត់ពុះទីងកាំ) របៀបរកប្រវែងវណ្ណមណ្ឌល់កេបន្ទាត់ពុះ កេកាំ ។ កេន័យផ្ទៃរង្វង់ សារគិតគូរកេផ្ទៃរង្វង់ កេកាំ ។

បរិច្ចណដ្ឋាន

នព្វន្ត

តាមកំណត់បែករជ្ជាកន្ទែខនេះជាខែចុងឆ្នាំសិក្សា ត្រូវសាបរៀនអំពីវិជ្ជាដែលបានបង្រៀនតាំងពីដើមឆ្នាំមក ហេតុនេះសូមលោកគ្រូ ដៃបរមើលវិជ្ជាត្រង់ណាដែលលោកគ្រូជ្រាប ថាសិស្សពុំទាន់យល់ច្បាស់ ឬ ពុំទាន់ចេះច្បាស់នោះយកមកបង្រៀនបញ្ជាក់ឲ្យសិស្សបានយល់បានចេះច្បាស់ឡើង ។

១វិញទៀត កូនសិស្សថ្នាក់នេះត្រូវឡើងទៅថ្នាក់គាទកដ្ឋាន ត្រូវចេះធ្វើចំណោទ ហេតុនេះសូមបង្ហាត់សិស្សឲ្យចេះធ្វើចំណោទឲ្យស្ទាត់ ។

ឯចំណោទនោះតាមតែលោកគ្រូគិតឲ្យសមល្មមនិងវិជ្ជារបស់សិស្សនៅថ្នាក់លោកគ្រូ ។

សូមជូនរបៀបពន្យល់ចំណោទជាគំរូខាងក្រោមនេះ ។

លោកគ្រូសរសេរចំណោទទុកនៅលើក្ដារខៀន ។

**បំណោទ** — ម្ដាយខ្ញុំមានប្រាក់ ៩៣ រៀល គាត់ទិញសំពត់ ៣ ម៉ែត្រអស់ ៤៧ រៀល ទិញអង្ករអស់ ២៥ រៀល ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានរៀលទៀត ។

របៀបបង្រៀន —

១ — ឲ្យសិស្សមើលសេចក្ដីចំណោទ - ( ២ ឬ ៣ នាក់ )

២ — សួរសាកពន្យល់ឲ្យសិស្សយល់សេចក្ដីចំណោទនោះ

៣ — សួរសាករបៀបធ្វើចំណោទនោះ

៤ — ឲ្យសិស្សធ្វើចំណោទនោះលើក្ដារខៀន ។

ការហាត់បញ្ជាក់ — តែងចំណោទថែមខាងលើនេះឲ្យសិស្សធ្វើនៅលើក្ដារខៀនល្បងមើល ។

ការហាត់បញ្ជាក់នៅក្នុងសៀវភៅ — សូមតែងជាចំណោទថែមខាងលើនេះឲ្យសិស្សធ្វើនៅក្នុងសៀវភៅ ។

---

## រង្វាស់ - រង្វាល់

ដូចជាក្បួនទូទៅដែរ រង្វាស់ - រង្វាល់ត្រូវសាបង្រៀនឡើងវិញអំពីវិជ្ជាដែលបានបង្រៀនរួចហើយ ។

របៀបសាបង្រៀនវិជ្ជានេះត្រូវនាំសិស្សហាត់វាស់ - វាល់ - ថ្លឹង ឲ្យបេះស្ទាតផង ត្រូវឲ្យបំបែកទៅជារង្វាស់ - រង្វាល់ទម្ងន់ធំជាងឬ តូចជាងប្រធានឲ្យស្ទាត់ ហើយតែងជាចំណោទឲ្យសិស្សធ្វើផង ។

## កុមារដ្ឋាន

### នព្វន្ត

សារៀន មេរៀនផ្សេងៗដែលបានរៀនតាំងពីដើមឆ្នាំ - ចំណោទផ្សេងៗ និងវិធីហាត់ធ្វើលេខ ។

### រង្វាស – រង្វាល់

សាបង្រៀនអំពីមេរៀនផ្សេងៗ ដែលបានបង្រៀនតាំងពីដើមឆ្នាំ - សូមនាំសិស្សគិតលេខនិងចំណោទផ្សេងៗឱ្យបានច្រើន ។

IMPRIMERIE
A. PORTAIL
PHNOM-PENH

TIRAGE 2.706 EX.